ភ្នំពេញ , ថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៣

**សារាចរលេខ ០៦ ស.រ**

រដ្ឋាភិបាលជាតិបណ្តោះអាសន្នកម្ពុជា

## សូមជំរាបមក

ឯកឧត្តម រដ្ឋមន្ត្រី អនុរដ្ឋមន្ត្រីគ្រប់ក្រសួង

ផ្អែកតាមសេចក្តីប្រកាសរបស់រដ្ឋាភិបាលជាតិបណ្តោះអាសន្នកម្ពុជា ចុះថ្ងៃទី ០២ ខែ កក្កដា ឆ្នាំ១៩៩៣ និងដើម្បីអោយរដ្ឋាភិបាលបានដឹងថា ឯកឧត្តមរដ្ឋមន្ត្រី អនុរដ្ឋមន្ត្រី គ្រប់ក្រសួងមានអវត្តមាននៅទីស្តីការ និងមូលហេតុ នៃការអវត្តមាននោះ សហប្រធានរដ្ឋាភិបាលជាតិបណ្តោះអាសន្នកម្ពុជា សូមជំរាបជូនឯកឧត្តម រដ្ឋមន្ត្រី អនុរដ្ឋមន្ត្រីគ្រប់ ក្រសួងថា នៅពេលណាដែលឯកឧត្តមមានភារកិច្ចបំពេញបេសកកម្ម ឬ សួរសុខទុក្ខ គ្រួសារ ឬ ភារកិច្ចចាំបាច់ នៅក្នុងប្រទេស ឬក្រៅប្រទេស ដោយអវត្តមាននៅកន្លែងទីស្តីការ សូមឯកឧត្តម ធ្វើលិខិតស្នើសុំអនុញ្ញាតច្បាប់ពីរដ្ឋាភិបាលជាតិបណ្តោះអាសន្នកម្ពុជា ។

លិខិតស្នើសុំអនុញ្ញាតច្បាប់របស់ឯកឧត្តម សូមស្នើផ្ញើមកទីស្តីការគណៈរដ្ឋមន្ត្រី អោយបាន ០៧ ថ្ងៃយ៉ាង តិចមុនថ្ងៃចេញដំណើរ ។

ក្រោយពីបានទទួលសារាចរនេះ សូមឯកឧត្តមរដ្ឋមន្ត្រី អនុរដ្ឋមន្ត្រី គ្រប់ក្រសួង ទទួលអនុវត្តចាប់ពីថ្ងៃ ឡាយព្រះហស្តលេខា និង ចុះហត្ថលេខាតទៅ ។

**សហប្រធាន**

រដ្ឋាភិបាលជាតិបណ្តោះអាសន្នកម្ពុជា

ព្រះហស្តលេខា ហត្ថលេខា

ស្តេចក្រុមហ្លួង **នរោត្តម រណឫទ្ធិ** **ហ៊ុន សែន**